សម្រាប់វ៉ាក់សាំង
ក្រុមហ៊ុន **Pfizer**
**(ខែ មីនា ឆ្នាំ2022)**

# សេចក្តីណែនាំអំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា
# (សម្រាប់ការចាក់ដូសជំរុញ(លើកទី3))

## អំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា
វ៉ាក់សាំងនេះគឺជាផ្នែកមួយនៃកម្មវិធីចាក់វ៉ាក់សាំងរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងតាមមូលដ្ឋានសម្រាប់ការបង្ការមេរោគកូរ៉ូណា (SARS-CoV-2)។ វ៉ាក់សាំងនេះត្រូវបានឧបត្ថម្ភដោយថវិកាសាធារណៈ ហើយការចាក់វ៉ាក់សាំងនេះនឹងមិនគិតថ្លៃឡើយ។ ការចាក់ដូសជំរុញ(លើកទី3) នេះគឺសម្រាប់អ្នកដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ។

## ប្រសិទ្ធភាពរបស់វ៉ាក់សាំង និងវិធីសាស្ត្រចាក់វ៉ាក់សាំង
វ៉ាក់សាំងដែលនឹងផ្តល់ជូនលើកនេះគឺបានផលិតឡើងដោយ Pfizer។ វ៉ាក់សុំាងនេះ នឹងបង្ការការចេញរោគសញ្ញានៃជំងឺឆ្លងកូវីដ19 គេបានរាយការណ៍មកថា ចំនួនអង់ទីករនឹងកើនឡើងច្រើនជាង បន្ទាប់ពីបានចាក់ដូសជំរុញនេះរួចក្នុងរយៈពេល1ខែក្រោយ បើធៀបនឹងចំនួនអង់ទីករដែលបានកើនឡើងនៅរយៈពេលដូចគ្នាបន្ទាប់ពីចាក់ដូសទី2។

| | |
|---|---|
| ឈ្មោះវ៉ាក់សាំង | ថ្នាំចាក់សាច់ដុំ Comirnaty |
| ប្រសិទ្ធផល និងប្រសិទ្ធភាព | ការបង្ការជំងឺឆ្លងដែលបង្កឡើងដោយវីរុស SARS-CoV-2 |
| ភាពញឹកញាប់ និងចន្លោះពេលវេលានៃការចាក់វ៉ាក់សាំង | 1ដង (ក្រោយចន្លោះពេលកំណត់ណាមួយបន្ទាប់ពីបញ្ចប់ការចាក់លើកទី2 )<br>*ការចាក់សាច់ដុំ |
| បុគ្គលដែលអាចចាក់វ៉ាក់សាំងបាន | អ្នកដែលអាយុចាប់ពី 12 ឆ្នាំឡើង |
| បរិមាណវ៉ាក់សាំង | 1 ដង= 0.3 ml (ចាក់ 1 ដង) |

- ដោយផ្អែកតាមច្បាប់ស្តីពីការចាក់វ៉ាក់សាំងបង្ការ រយៈពេលនៃការចាក់ដូសជំរុញគឺមានគម្លាតខុសគ្នាទៅតាមបុគ្គលនីមួយៗ (បច្ចុប្បន្នគឺចន្លោះពី 6-8ខែ)។ សូមពិនិត្យមើល សេចក្តីជូនដំណឹងពីអាជ្ញាធរមូលដ្ឋានក្នុងតំបន់ដែលអ្នករស់នៅ។
- វ៉ាក់សាំងនេះអាចចាក់បានដោយ មិនគិតពីប្រភេទវ៉ាក់សាំងដែលបានចាក់នៅលើកទី1 ឬលើកទី2 ឡើយ។
- ទោះបីជាបានចាក់វ៉ាក់សាំងនេះជាដូសជំរុញក៏ដោយ ក៏មិនប្រាកដថាអាចការពារការឆ្លងបានទាំងស្រុងឡើយ។ ការបន្តអនុវត្តវិធានការទប់ស្កាត់ការឆ្លងដែលសមស្រប គឺជារឿងចាំបាច់ទោះបីជាបានឬ មិនបានចាក់វ៉ាក់សាំងក៏ដោយ។ ម្យ៉ាងទៀត ការអនុវត្តវិធានការទប់ស្កាត់ការឆ្លងសមស្របជាបន្តទៀត គឺជារឿងចាំបាច់ទោះបីជាបានចាក់ឬមិនបានចាក់វ៉ាក់សាំងក៏ដោយ។

## បុគ្គលដែលមិនអាចចាក់វ៉ាក់សាំងបាន
វ៉ាក់សាំងនេះមិនអាចផ្តល់ជូនបុគ្គលដែលមានលក្ខណៈដូចខាងក្រោមឡើយ។
សូមផ្តល់ដំណឹងដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះយោបល់មុនពេលចាក់វ៉ាក់សាំង
ប្រសិនបើអ្នកគិតថាលក្ខខណ្ឌណាមួយត្រូវនឹងស្ថានភាពរបស់អ្នក។
- បុគ្គលដែលមានគ្រុនក្តៅ (*1)
- បុគ្គលដែលមានជំងឺស្រួចស្រាល់ធ្ងន់ធ្ងរ
- បុគ្គលដែលធ្លាប់មានប្រវត្តិមានប្រតិកម្មធ្ងន់ធ្ងរ (*2) ជាមួយនឹងសារធាតុផ្សំនៃវ៉ាក់សាំងនេះ។
- បុគ្គលដែលមានលក្ខណៈដទៃក្រៅពីលក្ខខណ្ឌខាងលើដែលមានលក្ខណៈមិនសមស្របក្នុងការទទួលបានវ៉ាក់សាំងនេះ។

(*1) គ្រុនក្តៅជាទូទៅមានសីតុណ្ហភាពចាប់ព 37.5 អង្សារសេ ឡើងទៅ។ ប៉ុន្តែ លក្ខខណ្ឌនេះមិនសមស្របសម្រាប់ករណីដែលជំងឺនេះត្រូវបានវាយតម្លៃជាគ្រុនក្តៅដោយពិចារណាលើសីតុណ្ហភាពរាងកាយធម្មតាឡើយ ទោះបីជារាងកាយមានសីតុណ្ហភាពទាបជាង 37.5 អង្សារក៏ដោយ។
(*2)ជំងឺប្រតិកម្មធ្ងន់ធ្ងរទាន់ហន់ និងរោគសញ្ញាមួយចំនួនដែលបង្ហាញពីជំងឺប្រតិកម្មថ្នាំនេះ រួមមានដូចជា របកស្បែក និងរោគសញ្ញាមានភ្នាសរអិល ពិបាកដកដង្ហើម ដង្ហើមខ្លី បេះដូងលោតញាប់ និងសម្ពាធឈាមខ្សោយ ជាដើម។ អ្នកដែលបានចេញរោគសញ្ញាដូចរៀបរាប់ខាងលើនេះបន្ទាប់ពីពេលចាក់លើកទី1 ឬលើកទី2 គឺមិនអាចចាក់ដូសជំរុញដោយប្រើវ៉ាក់សាំងដូចគ្នាឡើយ។

## បុគ្គលដែលត្រូវប្រុងប្រយ័ត្នក្នុងការចាក់វ៉ាក់សាំង
បុគ្គលដែលមានលក្ខណៈដូចខាងក្រោមគួរតែប្រុងប្រយ័ត្នក្នុងការចាក់វ៉ាក់សាំងនេះ។ ប្រសិនបើអ្នកគិតថាខ្លួនមានលក្ខណៈដូចខាងក្រោមនេះ សូមផ្តល់ដំណឹងដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះមុនពេលចាក់វ៉ាក់សាំង។
- បុគ្គលដែលកំពុងព្យាបាលការកកឈាម បុគ្គលដែលមានប្លាកែតថយចុះ ឬជំងឺកកឈាម។
- បុគ្គលដែលធ្លាប់ពិនិត្យឃើញថាខ្វះភាពស៊ាំ ឬបុគ្គលដែលមានសាច់ញាតិជិតស្និទ្ធខ្វះភាពស៊ាំពីកំណើត។
- បុគ្គលដែលមានជំងឺជាប់ខ្លួនស្រាប់ដូចជា ជំងឺបេះដូង តម្រងនោម ថ្លើម ជំងឺឈាម ឬ ជំងឺពាក់ព័ន្ធនឹងការលូតលាស់ ជាដើម។
- បុគ្គលដែលធ្លាប់ចាក់វ៉ាក់សាំងពីមុនមក ហើយកើតមានរោគសញ្ញាអាឡាក់ហ្ស៊ី ដូចជា គ្រុនក្តៅ ឬរមាស់ស្បែកនៅក្នុងអំឡុងពេល 2
- ថ្ងៃបន្ទាប់ពីការចាក់វ៉ាក់សាំង។
- បុគ្គលដែលធ្លាប់មានជំងឺប្រកាច់កាលពីមុន
- បុគ្គលដែលអាចនឹងអាឡាក់ហ្ស៊ីជាមួយនឹងសារធាតុផ្សំនៃវ៉ាក់សាំងនេះ។

ប្រសិនបើអ្នកមានផ្ទៃពោះ ឬអាចមានផ្ទៃពោះ ឬកំពុងបំបៅកូនដោយទឹកដោះ សូមផ្តល់ដំណឹងជូនដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះយោបល់មុនពេលចាក់វ៉ាក់សាំង។ យ៉ាងណាមិញ ក្នុងករណីអ្នកមិនបានពិគ្រោះយោបល់ជាមួយគ្រូពេទ្យសម្ភពប្រចាំខ្លួន អ្នកអាចចាក់វ៉ាក់សាំងនេះបាន ប្រសិនបើអ្នកត្រូវបានវិនិច្ឆ័យអនុញ្ញាតដោយគ្រូពេទ្យត្រួតពិនិត្យវេជ្ជសាស្ត្របឋម។

វ៉ាក់សាំងនេះមានផ្ទុកសារធាតុបន្ថែមដែលមិនធ្លាប់មានប្រើនៅក្នុងវ៉ាក់សាំងពីមុនៗមកឡើយ។ ប្រសិនបើអ្នកធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរ ឬអាឡាក់ហ្ស៊ី ជាមួយនឹងថ្នាំពីមុនមក សូមផ្តល់ដំណឹងជូនដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះយោបល់មុនពេលចាក់វ៉ាក់សាំង។

## សកម្មភាពដែលត្រូវធ្វើបន្ទាប់ពីទទួលបានវ៉ាក់សាំង
- បន្ទាប់ពីចាក់វ៉ាក់សាំងនេះរួច សូមរង់ចាំនៅទីតាំងដែលអ្នកចាក់ថ្នាំនោះឱ្យបានយ៉ាងហោច 15 នាទី (យ៉ាងហោច 30 នាទីសម្រាប់បុគ្គលដែលធ្លាប់មានរោគសញ្ញាអាឡាក់ហ្ស៊ីធ្ងន់ធ្ងរ ដូចជាជំងឺប្រតិកម្មថ្នាំ ឬបុគ្គលដែលមានអារម្មណ៍មិនស្រួលខ្លួន ឬសន្លប់ ជាដើម។) ប្រសិនបើអ្នក មានអារម្មណ៍មិនស្រួលខ្លួន សូមទាក់ទងទៅកាន់វេជ្ជបណ្ឌិតរបស់អ្នកភ្លាមៗ។ (ធ្វើបែបនេះអាចជួយឱ្យអ្នកអាចឆ្លើយតបទៅនឹងផលប៉ះពាល់ដែលអាចកើតមានឡើងភ្លាមៗនោះ)
- កន្លែងដែលចាក់ថ្នាំគួរតែរក្សាឱ្យស្អាត។ ទោះបីជាការអ្នកអាចងូតទឹកនៅថ្ងៃដែលចាក់ថ្នាំនោះបានក៏ដោយ ក៏អ្នកមិនត្រូវដុសកន្លែងដែលចាក់ថ្នាំនោះដែរ។
- សូមកុំធ្វើការហាត់ប្រាណខ្លាំងនៅថ្ងៃចាក់ថ្នាំនោះ។

**(បន្តទៅខាងក្រោយ)**

**ផលប៉ះពាល់**

- ផលប៉ះពាល់ចម្បងមានដូចជា ការឈឺចាប់នៅកន្លែងដែលចាក់ថ្នាំនោះ ឈឺក្បាល ឈឺសន្លាក និងឈឺសាច់ដុំ អស់កម្លាំង រងារ និងគ្រុនក្តៅ។ ផលប៉ះពាល់ដែលកម្រនឹងកើតឡើង ហើយមានភាពធ្ងន់ធ្ងរមានដូចជា ជំងឺចុះសម្ពាធឈាម (shock) ឬប្រតិកម្មថ្នាំ។ ដោយសារវ៉ាក់សាំងនេះគឺជាវ៉ាក់សាំងប្រភេទថ្មី ទើបថ្នាំនេះអាចនឹងបង្កឱ្យមានរោគសញ្ញាដែលមិនទាន់អាចបញ្ជាក់ច្បាស់ រហូតមកដល់ពេលនេះ។ ប្រសិនបើអ្នក កត់សម្គាល់ឃើញមានរោគសញ្ញាណាមួយបន្ទាប់ពីការចាក់វ៉ាក់សាំងរួច សូមពិគ្រោះជាមួយនឹងវេជ្ជបណ្ឌិតដែលចាក់វ៉ាក់សាំងនោះ ឬ វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់អ្នក។

- ត្បិតជាករណីកម្រខ្លាំង ក៏មានការរាយការណ៍ពីករណីសង្ស័យ ស្តីពីការរលាកសាច់ដុំបេះដូងនិង រលាកស្រោមបេះដូងក្រោយការចាក់វ៉ាក់សាំង ដូសមូលដ្ឋាននេះ(លើកទី1/លើកទី2 នេះផងដែរ(លើកទី1/លើកទី2) (*)។ បើមានលេចចេញរោគសញ្ញាដូចជា ឈឺទ្រូងឬបេះដូងលោតខ្លាំង ដង្ហើមខ្លី ការហើម ជាដើម ក្នុងរង្វង់ប៉ុន្មានថ្ងៃក្រោយចាក់ សូមទៅទទួលការពិនិត្យពីស្ថាបនវេជ្ជសាស្ត្រឲ្យបានឆាប់រហ័ស។
(*) ករណីនេះមានទំនោរកើតឡើងនៅក្រោយការចាក់លើកទី 2 ច្រើនជាងការចាក់លើកទី 1 ហើយភាគច្រើនកើតចំពោះមនុស្សវ័យក្មេង ជាពិសេសគឺបុរស។
- បើនៅក្នុងការចាក់ដូសជំរុញនេះ របាយការណ៍បានបង្ហាញថា ជាទូទៅមានការឡើងកូនកណ្តុរក្រោមក្លៀកច្រើន (ប្រមាណ5%) បើធៀបទៅនឹងការចាក់លើកទី1 ឬទី2។ រោគសញ្ញាភាគច្រើនគឺស្រាល នឹងបាត់ទៅវិញក្នុងរង្វង់ប៉ុន្មានថ្ងៃក្រោយ ប៉ុន្តែបើនៅឡើងហើមខ្លាំង ឬបន្តយូរ សូមទៅពិនិត្យនៅស្ថាបនវេជ្ជសាស្ត្រ។

**អំពីប្រព័ន្ធជំនួយសម្រាប់ការរងផលប៉ះពាល់ដល់សុខភាពដោយសារការចាក់វ៉ាក់សាំង**

ការចាក់វ៉ាក់សាំងអាចបង្កឱ្យមានបញ្ហាសុខភាព (ជំងឺផ្សេងៗ ឬពិការភាព)។ ទោះបីជាករណីកម្រ ប៉ុន្តែក៏មិនអាចសន្មត់ថាគ្មានទាំងស្រុងបានឡើយ ហេតុនេះទើបប្រព័ន្ធជំនួយនេះត្រូវបានបង្កើតឡើង។
នៅក្នុងករណីដែលមានការប៉ះពាល់ដល់សុខភាពដោយសារតែការចាក់វ៉ាក់សាំង ជំនួយ (ចំណាយលើការព្យាបាល ប្រាក់អត្ថប្រយោជន៍ជនពិការ ជាដើម) ក៏មានផ្តល់ជូនផងដែរនៅក្រោមច្បាប់នៃការចាក់វ៉ាក់សាំង។
សូមពិគ្រោះជាមួយនឹងភូមិ សង្កាត់ ក្រុងរបស់អ្នកអំពីនីតិវិធីចាំបាច់សម្រាប់ការបំពេញបែបបទ។

---

**អំពីការឆ្លងមេរោគកូវីដ**

នៅពេលដែលឆ្លងវីរុស SARS-CoV-2 អ្នកអាចនឹងមានរោគសញ្ញាស្រដៀងនឹងជំងឺផ្តាសាយ ដូចជា គ្រុនក្តៅ និងក្អក ជាដើម។ ទោះបីជាមានមនុស្សជាច្រើនបានធូរស្រាលពីជំងឺនេះដោយមានរោគសញ្ញាតិចតួចក្តី នៅក្នុងករណីធ្ងន់ធ្ងរមួយចំនួន រោគសញ្ញារលាកសួត ដូចជាពិបាកដកដង្ហើមខ្លាំងទៅៗ ហើយថែមទាំងអាចគ្រោះថ្នាក់ដល់អាយុជីវិតថែមទៀត។

**លក្ខណៈសម្គាល់របស់វ៉ាក់សាំងមេរោគកូវីដ (វ៉ាក់សាំងផលិតដោយ Pfizer) ដែលនឹងយកមកប្រើប្រាស់នៅលើកនេះ**

ថ្នាំនេះគឺជាវ៉ាក់សាំង RNA នាំសារ (mRNA) ហើយជាការផ្សំ ដែល mRNA ដែលជាផែនការសម្រាប់ប្រូតេអ៊ីនសំខាន់នៃវីរុស SARS-CoV-2 (ប្រូតេអ៊ីនដែលមេរោគត្រូវការចាំបាច់ដើម្បីចូលទៅក្នុងកោសិការាងកាយ) មានព័ទ្ធជុំវិញនៅក្នុងភ្នាសលីពីត។ នៅពេលដែល mRNA ចូលទៅដល់កោសិការបស់មនុស្សតាមរយៈវ៉ាក់សាំងដែលមាននៅក្នុងថ្នាំនេះ ប្រូតេអ៊ីនបន្លាមេរោគ (viral spike proteins) នឹងកកើតឡើងនៅក្នុងកោសិកាអាស្រ័យទៅតាម mRNA ហើយធ្វើឱ្យអង់ទីករអស់ប្រសិទ្ធភាពក្នុងការប្រឆាំងនឹងប្រូតេអ៊ីនបន្លា ថែមទាំងបង្កើតឱ្យមានការឆ្លើយតបការពារកោសិកា ដែលគេបានជឿថាអាចបង្ការការឆ្លងជំងឺដែលបណ្តាលមកពីវីរុស SARS-CoV-2 បាន។

ថ្នាំនេះមានផ្សំឡើងពីគ្រឿងដូចខាងក្រោម៖

| | |
|---|---|
| សារធាតុផ្សំសកម្ម | ◆ Tozinameran (mRNA បង្កើតឱ្យមានប្រូតេអ៊ីនបន្លាពេញលក្ខណៈដែលភ្ជាប់ជាមួយនឹងភ្នាសកោសិការបស់មនុស្ស) |
| ធាតុផ្សំបន្ថែម | ◆ សមាសធាតុ ALC-0315: [(4-hydroxybutyl)azanediyl]bis(hexane-6,1-diyl)bis(2-hexyldecanoate)<br>◆ សមាសធាតុ ALC-0159: 2-[(polyethylene glycol)-2000]-N,N-ditetradecylacetamide<br>◆ សមាសធាតុ DSPC: 1,2-Distearoyl-sn-glycero-3-phosphocholine<br>◆ កូលេស្តេរ៉ូល ◆ ប៉ូតាស្យូម ក្លរីត ◆ផូស្វ័រម៉ូណូគ្រូប៉ូតាស្យូម<br>◆ សូដ្យូមហ្វ្រីដ្យូមផូស្វូមឌីដ្រូស៊ីត ◆ ស្ករ |

សម្រាប់ព័ត៌មានបន្ថែមអំពីប្រសិទ្ធភាព និងសុវត្ថិភាពរបស់វ៉ាក់សាំងសម្រាប់មេរោគកូវីដ សូមចូលទៅកាន់ទំព័រវ៉ាក់សាំងសម្រាប់មេរោគកូវីដនៅលើវែបសាយរបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព។

ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព វ៉ាក់សាំងមេរោគកូវីដនា | ស្វែងរក

ប្រសិនបើអ្នកមិនអាចបើកវែបសាយនោះបានទេ សូមទាក់ទងទៅកាន់សាលាក្រុងក្នុងមូលដ្ឋានរបស់អ្នក។